វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ក្រសួងផែនការ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
IDRC | CRDI
ទីស្តីការគណៈរដ្ឋមន្ត្រី
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សង្ខេបសម្រាប់ គោលនយោបាយ

ឆ្នាំ ២០១២ លេខ ០៨


# ភាពងាយរងគ្រោះនៃគ្រួសារ ចំពោះវិបត្តិហិរញ្ញវត្ថុសាកល និងយុទ្ធសាស្ត្រដោះស្រាយ៖ ភស្តុតាងបានពី ៩ភូមិ នៅកម្ពុជា


*សាំង ច័ន្ទហង្ស*[១]


## សេចក្តីផ្តើម

គ្រួសារអ្នកជនបទនៅកម្ពុជា ក៏ដូចជាក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់ ងាយរងគ្រោះដោយការប៉ះទង្គិចផ្សេងៗតាមគ្រួសារនីមួយៗ (idiosyncratic shocks) ដូចជា ការបាត់បង់ជីវិត និងជំងឺធ្ងន់ធ្ងរ ព្រមទាំងការប៉ះទង្គិចជារួម (covariate shocks) ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត (World Bank 2006a: 53, 16-18)។ កង្វះប្រាក់សន្សំ និងទ្រព្យជាប់លាប់ និងលទ្ធភាពតិចក្នុងការបានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន សេវាអប់រំនិងថែទាំសុខភាព ការគាំពារខាងសង្គមកិច្ច និងប្រព័ន្ធសុវត្ថិភាព ជាកត្តាដ៏សំខាន់ ដែលធ្វើឲ្យពួកគាត់គ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីទប់ទល់នឹងវិបត្តិនានា (World Bank 2006b: 53, 13-15)។ អត្ថបទនេះ បកស្រាយពីមូលហេតុដែលភាពក្រីក្រនៅមានកម្រិតខ្ពស់ក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាលនៅកម្ពុជា៖ នៅឆ្នាំ២០០៧ អត្រាភាពក្រីក្រនៅតំបន់ជនបទមានដល់ ៣៤,៧% គឺខ្ពស់ជាងនៅ ភ្នំពេញ (០,៨%) និងតំបន់ទីប្រជុំជននានា (២១,៩%) (World Bank 2009: 27)។ ការរីករាលដាលវិបត្តិហិរញ្ញវត្ថុសាកលនៅឆ្នាំ២០០៩ នាំឲ្យមានការព្រួយបារម្ភកាន់តែច្រើនពីផលប៉ះពាល់របស់វាទៅលើគ្រួសារនៅជនបទ។ អត្ថបទសង្ខេបគោលនយោបាយនេះ នឹងជួយបំភ្លឺពីកម្រិតងាយរងគ្រោះរបស់គ្រួសារនៅជនបទ ចំពោះវិបត្តិហិរញ្ញវត្ថុសាកល និងប្រសិទ្ធភាពនៃយុទ្ធសាស្ត្រ ដែលពួកគាត់បានប្រើប្រាស់ទប់ទល់នឹងវិបត្តិ។

## ទិន្នន័យ និងវិធីសាស្ត្រ

ការសិក្សានេះប្រើប្រាស់ទិន្នន័យបានពី អង្កេតចំនួនពីរតាមពេលជាបន្តបន្ទាប់ដែលធ្វើឡើងនៅខែមីនា ២០០៨ និងខែមីនា ២០១១ ទៅលើប្រជាជន ៩៥៦គ្រួសារ មកពី ៩ភូមិ ក្នុង ៤ តំបន់៖ តំបន់ទំនាបទន្លេមេគង្គ (ភូមិបាបោង ក្នុងខេត្តព្រៃវែង និងភូមិព្រែកក្មេង ក្នុងខេត្តកណ្តាល) តំបន់ទំនាបទន្លេសាប (ភូមិទួលក្រសាំង និងភូមិអណ្តូងត្រាច ក្នុងខេត្តបាត់ដំបង និងភូមិខ្សាច់ជីរស់ ក្នុងខេត្តកំពង់ធំ) តំបន់ខ្ពង់រាប (ភូមិដងក្តារ ក្នុងខេត្តកំពង់ធំ ភូមិកញ្ជរ ក្នុងខេត្តក្រចេះ និងភូមិត្រពាំងប្រីយ៍ ក្នុងខេត្តកំពង់ស្ពឺ) និងតំបន់ឆ្នេរ (ភូមិកំពង់ត្នោត ក្នុងខេត្តកំពត)។ ការវិភាគបែបពិពណ៌នាលើលទ្ធផលអង្កេត ផ្តោតលើ បម្រែបម្រួលចំណាយប្រើប្រាស់ប្រចាំថ្ងៃ ក្នុងមនុស្សម្នាក់ នៅមុន និងនៅក្រោយវិបត្តិហិរញ្ញវត្ថុ នៅតាមភូមិនានា និងតាមក្រុមទសភាគចំណាយប្រើប្រាស់ (consumption deciles)។ ការសិក្សាក៏បានប្រើប្រាស់ម៉ូដែលសេដ្ឋកិច្ចមាត្រសាស្ត្រ (econometric models) ដើម្បីប៉ាន់ស្មានអំពីកម្រិតភាពងាយរងគ្រោះរបស់គ្រួសារ និងប្រសិទ្ធភាពនៃយុទ្ធសាស្ត្រទប់ទល់វិបត្តិ។

## លទ្ធផលស្រាវជ្រាវ

### ការពិពណ៌នាបែបវិភាគ

ទិន្នន័យអំពី បម្រែបម្រួលចំណាយប្រើប្រាស់ប្រចាំថ្ងៃក្នុងមនុស្សម្នាក់ នៅតាមភូមិជាសំណាកទាំង ៩ នៅមុននិងនៅក្រោយវិបត្តិហិរញ្ញវត្ថុសាកល បានបង្ហាញថា គ្រួសារស្ទើរតែទាំងអស់ លើកលែងតែនៅភូមិអណ្តូងត្រាច បានជួបកង្វះខាតចំណាយប្រើប្រាស់យ៉ាងធ្ងន់ធ្ងរ។ ភូមិត្រពាំងប្រីយ៍ ដែលជាភូមិមួយមានឱនភាពស្រូវ បានរងការប៉ះទង្គិចខ្លាំងជាងគេពីវិបត្តិ ដោយចំណាយប្រើប្រាស់ធ្លាក់ចុះ ៤៨,៨% រីឯភូមិផ្សេងទៀត បានធ្លាក់ចុះចំណាយប្រើប្រាស់ ២០-៣០%។ ដោយមានទីតាំងនៅជិតព្រំប្រទល់ប្រទេសថៃ ភូមិអណ្តូងត្រាច ជាករណីប្លែកពីគេ ព្រោះមានលទ្ធភាពទាញយកប្រយោជន៍ពីចំណាកស្រុកកម្លាំងពលកម្មទៅប្រទេសថៃ ហើយអាចការពារខ្លួនពីវិបត្តិបានខ្លះ។ ទោះយ៉ាងនេះក្តី ការពិនិត្យលំអិតពីបម្រែបម្រួលក្នុងចំណាយប្រើប្រាស់តាម ១០ក្រុមទសភាគ បង្ហាញថា គ្រួសារស្ទើរតែទាំងអស់បានរងការប៉ះ

[១] លោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវ កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅវិទ្យាស្ថាន CDRI។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

តារាង ១៖ ចំណាយប្រើប្រាស់ប្រចាំថ្ងៃក្នុងមនុស្សម្នាក់ គិតជារៀល ឆ្នាំ២០០៨-២០១១ (ថ្លៃថេរឆ្នាំ២០០៥)

| ក្រុមទសភាគ | 2008 | 2011 | បម្រែបម្រួលជា % |
|---|---|---|---|
| 1 (ទាបបំផុត) | 1264.5 | 959.1 | -24.1 |
| 2 | 1735.1 | 1345.8 | -22.4 |
| 3 | 2046.8 | 1616.9 | -21.0 |
| 4 | 2330.0 | 1821.4 | -21.8 |
| 5 | 2617.2 | 2017.0 | -22.9 |
| 6 | 2914.7 | 2245.2 | -23.0 |
| 7 | 3257.0 | 2549.6 | -21.7 |
| 8 | 3756.7 | 2938.3 | -21.8 |
| 9 | 4704.7 | 3654.3 | -22.3 |
| 10 (ខ្ពស់បំផុត) | 8370.7 | 5741.4 | -31.4 |
| ភូមិទាំងអស់ | 3296.0 | 2486.43 | -24.6 |

ប្រភព៖ អង្កេតគ្រួសារអនុវត្តដោយវិទ្យាស្ថាន CDRI នៅឆ្នាំ ២០០៨ និង ២០១១

ទង្គិចពីវិបត្តិ ដោយចំណាយប្រើប្រាស់ជាមធ្យម បានធ្លាក់ចុះ ២៤,៦% (តារាង ១)។

## ការវិភាគផ្អែកលើបទពិសោធន៍ជាក់ស្តែង

ការសិក្សារកឃើញថាគ្រួសារមានសមាជិកច្រើនទំនងងាយរងគ្រោះពីវិបត្តិហិរញ្ញវត្ថុសាកល ខ្លាំងជាងគ្រួសារមានសមាជិកតិច។ នេះបង្ហាញថាទ្រឹស្តីសេដ្ឋកិច្ចមាត្រសាស្ត្រ (economiesofscale) ពុំមានឥទ្ធិពលទេនៅក្នុងចំណាយប្រើប្រាស់។ មេគ្រួសារមានវ័យចំណាស់ តែងមានលទ្ធភាពការពារខ្លួនតិចជាងក្នុងពេលមានវិបត្តិ រីឯមេគ្រួសារមានការអប់រំល្អអាចការពារខ្លួនបានល្អជាងព្រោះគាត់ច្រើនមានការងារធ្វើជាប់លាប់។ ចំណុចគួរភ្ញាក់ផ្អើល គឺគ្រួសារមានស្ត្រីជាមេគ្រួ និងគ្រួសារមានប្តីប្រពន្ធ ទំនងមានការការពារច្រើនទល់នឹងវិបត្តិហិរញ្ញវត្ថុសាកល។ គ្រួសារមានសមាជិកវ័យចាស់ច្រើននាក់ តែងងាយរងគ្រោះខ្លាំងជាងពីវិបត្តិ ប៉ុន្តែគ្រួសារមានកុមារអាយុក្រោម ១៤ឆ្នាំច្រើន អាចទប់ទល់នឹងវិបត្តិបានល្អជាង ពីព្រោះកុមារប្រហែល ៥% ជាកម្លាំងពលកម្មសកម្ម ក្នុងនេះមានមួយភាគបី រៀនសូត្រផង និងធ្វើការផង។ ការបញ្ជូនកុមារទៅធ្វើការ ទំនងជួយដល់ជីវភាពគ្រួសារក្នុងអំឡុងពេលមានវិបត្តិ ប៉ុន្តែវារារាំងកុមារក្នុងការរីកលូតលាស់ បានពេញលេញល្អផ្នែករាងកាយ និងការយល់ដឹង។

មិនមានភស្តុតាងអ្វីបង្ហាញថា វិបត្តិហិរញ្ញវត្ថុសាកលបណ្តាលឲ្យគ្រួសារដែលធ្វើការងារក្នុងវិស័យកសិកម្ម និងសេវាកម្ម ធ្លាក់ចូលក្នុងភាពងាយរងគ្រោះនោះទេ ប៉ុន្តែលទ្ធផលសិក្សាបានផ្តល់គំនិតថា គ្រួសារប្រកបរបរលក់ទំនិញរាយ កាន់តែងាយរងគ្រោះខ្លាំងឡើង។ គ្រួសារដែលមានជីវភាពល្អប្រសើរ (ផ្ទះមានជញ្ជាំងធ្វើពីឥដ្ឋឬឈើ មានសម្ភារៈប្រើប្រាស់ក្នុងផ្ទះច្រើន និងមានសត្វចិញ្ចឹម) តែងមិនសូវងាយរងគ្រោះទេ ប៉ុន្តែគ្រួសារមានការប្រើប្រាស់ធនធានទ្រព្យរួម ហាក់ដូចងាយរងគ្រោះជាង។

ក្នុងចំណោមយុទ្ធសាស្ត្រទប់ទល់វិបត្តិ ដែលបានវិភាគក្នុងការសិក្សានេះ មានតែការលក់ដីទំនេរប៉ុណ្ណោះទេដែលត្រូវបានបញ្ជាក់ថាមានប្រសិទ្ធភាព។ រីឯ ទ្រព្យជាមធ្យោបាយដឹកជញ្ជូន សម្ភារៈប្រើប្រាស់ក្នុងផ្ទះ សម្ភារៈកសិកម្ម សត្វចិញ្ចឹម ទំហំប្រាក់កម្ចីប្រព័ន្ធផ្ទេរប្រាក់ (ជំនួយបានពីសាច់ញាតិ ឬមិត្តភក្តិ) ឬការលក់ដីកសិកម្ម ពុំមានតួលេខមេគុណអ្វីដែលមានសារៈសំខាន់ផ្នែកស្ថិតិទេ ដូច្នេះយន្តការទប់ទល់វិបត្តិទាំងអស់នេះ មិនមានប្រសិទ្ធភាពសម្រាប់ការជួយសម្រួលចំណូលគ្រួសារឡើយ។

## សន្និដ្ឋាន

ការសិក្សានេះរកឃើញថាវិបត្តិហិរញ្ញវត្ថុសាកលបានដាក់បន្ទុកធ្ងន់ធ្ងរទៅលើគ្រួសារក្នុងភូមិទាំង ៩ និងលើគ្រប់ប្រភេទគ្រួសារ។ គ្រួសារមានសមាជិកច្រើន និងគ្រួសារមានសមាជិកវ័យចំណាស់ច្រើនតែងងាយរងគ្រោះខ្លាំងជាងគ្រួសារដទៃទៀតពីវិបត្តិហិរញ្ញវត្ថុសាកល។ គ្រួសារមានកុមារអាយុក្រោម ១៤ឆ្នាំច្រើន មានការការពារល្អទល់នឹងវិបត្តិ ប៉ុន្តែការធ្វើពលកម្ម ក៏នាំឲ្យ កុមារមិនបានទៅសាលារៀន ដែលជាយន្តការសម្រាប់ទប់ទល់ក្នុងរយៈពេលវែងនោះដែរ។ ការសិក្សារកឃើញទៀតថា ពុំមានយន្តការទប់ទល់វិបត្តិប្រកបដោយប្រសិទ្ធភាព អ្វីដែលគ្រួសារបានប្រើប្រាស់ទេ ដូច្នេះគេឃើញច្បាស់ពីតម្រូវការបន្ទាន់របស់គ្រួសារនានានូវជំនួយ និងការការពារពីសំណាក់រដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ។